# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២០-១០-២០១១ -ព្រះរាជក្រឹត្យ នស/រកត/១០១១/៩៣៧ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម សាន ខណ្ឌស៊ី ពីទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា ៧៩៨៥

២០-១០-២០១១ -ព្រះរាជក្រឹត្យ នស/រកត/១០១១/៩៣៨ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម ម៉ិន ស៊ីនាថ ពីជំនួយការសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា តាមសំណើសាមីខ្លួន ៧៩៨៦

២៨-១០-២០១១ -ព្រះរាជក្រឹត្យ នស/រកត/១០១១/៩៤០ ស្តីពី ការតែងតាំង ឯកឧត្តម ម៉ុន សាម៉ាន់ ជាទីប្រឹក្សាអមក្រសួងសាធារណការ និង ដឹកជញ្ជូន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៧៩៨៧

២៨-១០-២០១១ -ព្រះរាជក្រឹត្យ នស/រកត/១០១១/៩៤១ ស្តីពី ការធ្វើវិសោធនកម្មមាត្រា ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី ០៩ ខែតុលា ឆ្នាំ ២០០៨ ស្តីពីវិសោធនកម្មមាត្រា ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ៧៩៨៨

## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

២៦-១០-២០១១-អនុក្រឹត្យលេខ ២៣៦ អនក្រ.បក ស្តីពី ការផ្ទេរគណទានថវិកា ៧៩៩១

២៨-១០-២០១១-អនុក្រឹត្យលេខ ២៣៧ អនក្រ.បក ស្តីពី ការផ្ទេរគណទានថវិកា ៧៩៩៣

២៨-១០-២០១១-អនុក្រឹត្យលេខ ២៣៨ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ២.៤៩៦ ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ៧៩៩៥

២៨-១០-២០១១-អនុក្រឹត្យលេខ ២៣៩ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៤.២៨០ ហិកតា ក្នុងតំបន់ឧទ្យានជាតិបុទមសាគរ ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តកោះកុង ៧៩៩៧

២៨-១០-២០១១-អនុក្រឹត្យលេខ ២៤០ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ២.៩៩៥ ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកប្រាសាទបាល័ង្ក និង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ៧៩៩៩

២៨-១០-២០១១-អនុក្រឹត្យលេខ ២៤១ អនក្រ.បក ស្ដីពី ការកំណត់លក្ខណៈសម្បត្តិ និង ឋានៈគ្រូនគរបាលជាតិ ៨០០១
២៦-១០-២០១១-អនុក្រឹត្យលេខ ១១៣៥ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៨០០៥
២៦-១០-២០១១-អនុក្រឹត្យលេខ ១១៣៦ អនក្រ.តត ស្ដីពី ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ ៨០០៦
២៧-១០-២០១១-អនុក្រឹត្យលេខ ១១៣៧ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៨០០៧
២៧-១០-២០១១-អនុក្រឹត្យលេខ ១១៣៨ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨០០៨
២៧-១០-២០១១-អនុក្រឹត្យលេខ ១១៣៩ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៨០០៩
២៧-១០-២០១១-អនុក្រឹត្យលេខ ១១៤០ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨០១០
២៧-១០-២០១១-អនុក្រឹត្យលេខ ១១៤១ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៨០១១
២៧-១០-២០១១-អនុក្រឹត្យលេខ ១១៤២ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨០១៣
២៧-១០-២០១១-អនុក្រឹត្យលេខ ១១៤៣ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៨០១៤
២៧-១០-២០១១-អនុក្រឹត្យលេខ ១១៤៤ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨០១៦
២៧-១០-២០១១-អនុក្រឹត្យលេខ ១១៤៥ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៨០១៧
២៧-១០-២០១១-អនុក្រឹត្យលេខ ១១៤៦ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៨០១៩
២៧-១០-២០១១-អនុក្រឹត្យលេខ ១១៤៧ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨០២១
២៧-១០-២០១១-អនុក្រឹត្យលេខ ១១៤៨ អនក្រ.តត ស្ដីពី ការដាក់ឱ្យចូលនិវត្តន៍ ៨០២៣
២៧-១០-២០១១-អនុក្រឹត្យលេខ ១១៤៩ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៨០២៦
២៧-១០-២០១១-អនុក្រឹត្យលេខ ១១៥០ អនក្រ.តត ស្ដីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៨០២៨
២៨-១០-២០១១-អនុក្រឹត្យលេខ ១១៥១ អនក្រ.តត ស្ដីពី ការទទួលស្គាល់សមាសភាព ក្រុមប្រឹក្សាគណៈឱសថការីជាតិសម្រាប់អាណត្តិទី ១ ៨០២៩
២៨-១០-២០១១-អនុក្រឹត្យលេខ ១១៥២ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៨០៣២
២៨-១០-២០១១-អនុក្រឹត្យលេខ ១១៥៣ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៨០៣៤
២៨-១០-២០១១-អនុក្រឹត្យលេខ ១១៥៤ អនក្រ.តត ស្ដីពី ការជូនមេដាយសហមេត្រី ៨០៣៦
២៨-១០-២០១១-អនុក្រឹត្យលេខ ១១៥៥ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨០៣៧
២៨-១០-២០១១-អនុក្រឹត្យលេខ ១១៥៦ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៨០៣៩

## ២-សេចក្ដីសម្រេច

០២-១១-២០១១-សេចក្ដីសម្រេចលេខ ៦០ សសរ ស្ដីពី ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់ ៨០៤២

# គ

## III~ការងារបណ្ដាក្រសួង

### ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


០១-១០-២០១០ -លិខិតបញ្ជាក់លេខ ៤៦២០ ពណ.ចបព ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ិន ស៊ាង ឌូត (ខេមបូឌា) អ៊ីមផត អិចផត លីមីធីត** ៨០៤៤

០១-១០-២០១០ -លិខិតបញ្ជាក់លេខ ៤៦២១ ពណ.ចបព ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផាត ខូវៀ ម៉ូធ័រ អ៊ីមផត អិចផត** ៨០៤៦

០១-១០-២០១០ -លិខិតបញ្ជាក់លេខ ៤៦២៤ ពណ.ចបព ស្ដីពីការទទួលចុះបញ្ជីនូវការកែប្រែ និងតំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **ស៊ូសខេត** ៨០៤៨

០១-១០-២០១០ -លិខិតបញ្ជាក់លេខ ៤៦៣១ ពណ.ចបព ការចុះបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ពេញលក្ខណៈច្បាប់របស់ **ការិយាល័យតំណាងពាណិជ្ជកម្មក្រុមហ៊ុន ខនស្ត្រាក់សិន ខនសាល់ធេន ឌីវេឡុបមេន អ៊ីបេន ស្កូត ខមភេនី (ខូដេស្កូ)** ៨០៥០

០១-១០-២០១០ -លិខិតបញ្ជាក់លេខ ៤៦៣២ ពណ.ចបព ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ.ស៊ី គួង ថៃ អ៊ីមផត អិចផត** ៨០៥១

០១-១០-២០១០ -លិខិតបញ្ជាក់លេខ ៤៦៣៤ ពណ.ចបព ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គេវ្ជ័យ ខូ អិលធីឌី** ៨០៥៣

០១-១០-២០១០ -លិខិតបញ្ជាក់លេខ ៤៦៣៥ ពណ.ចបព ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង្គារបុត្រ ប៊ីហ្សនេស គ្រុប អិលធីឌី** ៨០៥៥

០១-១០-២០១០ -លិខិតបញ្ជាក់លេខ ៤៦៣៦ ពណ.ចបព ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **នីហ្វាមី** ៨០៥៧

០១-១០-២០១០ -លិខិតបញ្ជាក់លេខ ៤៦៤៦ ពណ.ចបព ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង្គរ គម្ពុ ធួរ** ៨០៥៩

# ព្រះរាជក្រឹត្យ

នស/រកត/១០១១/៩៣៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **សាន ចន្ទ្រាស៊ី** ពីទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ចរស. ១១១០.៩៥៤

លេខ ៩០... ប.ល
...ជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០១១
...រាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១១/៩៣៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានបញ្ចប់មុខតំណែងឯកឧត្តម **ចិន ស៊ីនាថ** ពីជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា តាមសំណើសាមីខ្លួន ។

**មាត្រា២ :** សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ពរស. ១១១០.៩៥៥

លេខ: ៩៦០៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ២០១១

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/១០១១/៩៤០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងឯកឧត្តម **ម៉ុន សាអ៊ាន់** ជាទីប្រឹក្សាអមក្រសួងសាធារណការ និង ដឹកជញ្ជូន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល. ១១១០.៩៥៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០១១

ការ ១០៧០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០១១
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

សយ សុខា

នស/រកត/១០១១/៩៤១

# ព្រះរាជក្រឹត្យ

## ស្តីពី

## វិសោធនកម្មមាត្រា ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីវិសោធនកម្មមាត្រា ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា មួយ**:

ត្រូវបានធ្វើវិសោធនកម្មមាត្រា ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា ១ នៃព្រះរាជក្រឹត្យលេខ

នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៦ ស្ដីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដូចតទៅ:

**មាត្រា ១ ថ្មី**: អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសមាសភាពដូចតទៅ:

| | |
|---|---|
| ១-តំណាង នាយករដ្ឋមន្ត្រី | ប្រធាន |
| ២-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធានទី១ |
| ៣-ឥស្សរជនមួយរូប | អនុប្រធានប្រចាំការ |
| ៤-ឥស្សរជនមួយចំនួន | អនុប្រធាន |
| ៥-រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ៦-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៨-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៩-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ១០-រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១១-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ១២-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣-រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៤-រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៥-អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១៦-អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១៧-មេបញ្ជាការកងទ័ពជើងគោក | សមាជិក |
| ១៨-មេបញ្ជាការកងទ័ពជើងទឹក | សមាជិក |
| ១៩-មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២០-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២១-មេធាវីរាជរដ្ឋាភិបាល | សមាជិក |
| ២២-អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត | សមាជិក |
| ២៣-តំណាងអង្គការក្រៅរដ្ឋាភិបាលសំខាន់ៗដែលពាក់ព័ន្ធ | សមាជិក |

សមាសភាពជាក់ស្តែងត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ពីរ:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា បី:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត.១០១១.៩៥៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៩០៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១១
**អគ្គលេខាធិការរងនៃទីស្តីការគណៈរដ្ឋមន្ត្រី ប្រចាំការ**

**សយ សុខា**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៣៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/ ០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១២១០ / ០១៧ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៦៩ អនក្រ. បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១**: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២៥៥ លានរៀល ( ពីររយហាសិបប្រាំលានរៀលគត់ ) ពីជំពូក ៦០( ការទិញ ) មកជំពូក ៦២ ( សេវាខាងក្រៅផ្សេងៗ )ជូនក្រសួងយុត្តិធម៌សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។

**មាត្រា២**: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់បំពេញតម្រូវការចំណាយធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់ឧត្តមមន្ត្រីច្បាប់អាស៊ានលើកទី ១៤ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងអគ្គរដ្ឋអាជ្ញាអាស៊ានលើកទី ៨ នៅឆ្នាំ ២០១១ នៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាអ្នកទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ២៣៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧, ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករនាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៦៩ អនក្រ.បក, ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១១
- បានឃើញប្រកាសលេខ ១១៩៦ សហវ.ប្រក, ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១
- លិខិតលេខ ១២៦៨ សណ.ប.ស្ត, ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១១ របស់ក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១** : ត្រូវបានអនុញ្ញាតឱ្យក្រសួងបរិស្ថានធ្វើការផ្ទេរឥណទានថវិកា ចំនួន ១.០៧១ លានរៀល ( មួយពាន់ចិតសិបមួយលានរៀលគត់ ) ពីជំពូក ៦០ ( ការទិញ ) ចំនួន ១៨៦ លានរៀល និងជំពូក ៦១ ( សេវាខាងក្រៅ ) ចំនួន ៨៨៥ លានរៀល មកជំពូក ៦២ ( សេវាខាងក្រៅផ្សេងៗ ) សម្រាប់ចំណាយរៀបចំកិច្ចប្រជុំក្រៅផ្លូវការលើកទី ១៣ ថ្នាក់រដ្ឋមន្ត្រីបរិស្ថានអាស៊ានក្នុង ឆ្នាំ ២០១១ ។

**មាត្រា២** : ការបែងចែកឥណទានថវិកាផ្ទេរក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែង របស់ក្រសួងបរិស្ថាន សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ ៨ ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ *ហ៊ុន សែន* នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ២៣៥ . អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ២.៤៩៦ ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្ដីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ១៨៦អនក្រ.បក ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១១ ស្ដីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា១:**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដី ទំហំ ២.៤៩៦ (ពីរពាន់បួនរយកៅសិបប្រាំមួយ) ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ក្រោមល័ក្ខខ័ណ្ឌជួល ឬ សម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់និងលិខិតលេខ ៩៣៥ សជណ.កស ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២:**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៣៩. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៤.២៨០ ហិកតា ក្នុងតំបន់ឧទ្យានជាតិបូទុមសាគរ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកោះកុង

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រតក/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ១៧១អនក្រ.បក ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា១:**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៤.២៨០ ( បួនពាន់ពីររយប៉ែតសិប) ហិកតា ក្នុងតំបន់ឧទ្យានជាតិបុទមសាគរ ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកោះកុង ក្រោមល័ក្ខខ័ណ្ឌជួល ឬសម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ទេសចរណ៍ ដូចមានក្នុងផែនទី និងនិយាមកាដែលជាឯកសារភ្ជាប់និងលិខិតលេខ ៧៣៩ សជណ.កស ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២:**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ៤
- -រាជកិច្ច
- -ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ២៤០.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ២.៩៩៥ ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកប្រាសាទបាល័ង្ក និងស្រុកសណ្តាន់ ខេត្តកំពង់ធំ

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ១៩៥អនក្រ.បក ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា១:**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដី ទំហំ ២.៩៩៥ (ពីរពាន់ប្រាំបួនរយកៅសិបប្រាំ) ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកប្រាសាទបាល័ង្ក ខេត្តកំពង់ធំ ក្រោមល័ក្ខខ័ណ្ឌជួល ឬ សម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម ដាំដំណាំកៅស៊ូ និងចិញ្ចឹមសត្វ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់និងលិខិតលេខ ៩១៦សជណ ចុះថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា២:**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤:**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ តុ ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ៤
- -រាជកិច្ច
- -ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៤១.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកំណត់លក្ខណៈសម្បត្តិ និងឋានៈគ្រូនគរបាលជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ

-បានឃើញ អនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៧ ស្តីពីការប្រែក្លាយសាលាភូមិន្ទនគរបាលទៅជាបណ្ឌិត្យសភានគរបាលកម្ពុជា

-យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១** : ត្រូវបានកំណត់លក្ខណៈសម្បត្តិនិងឋានៈគ្រូនគរបាលជាតិ ។ ការកំណត់នេះក្នុងគោលបំណងលើកកំពស់គុណភាពគ្រូនគរបាលជាតិ សំដៅបង្កើនប្រសិទ្ធភាពការងារបណ្តុះបណ្តាល និង ការអភិវឌ្ឍធនធានមនុស្សក្នុងជួរមន្ត្រីនគរបាលជាតិ ឱ្យបានសមស្របទៅនឹងការរីកចម្រើនរបស់ប្រទេសជាតិ ។ គ្រូនគរបាលជាតិត្រូវស្ថិតក្រោមការគ្រប់គ្រងពីបណ្ឌិត្យសភានគរបាលកម្ពុជា ។

**មាត្រា២ :** គ្រូនគរបាលជាតិមានតួនាទី ភារកិច្ច សិក្សាស្រាវជ្រាវ អប់រំ និងបណ្តុះបណ្តាល ជូនដល់សិស្ស និស្សិត កម្មសិក្សាការី និងនគរបាលជាតិគ្រប់លំដាប់ថ្នាក់ ។

**មាត្រា៣ :** គ្រូនគរបាលជាតិត្រូវបានបែងចែកជា ៣ កម្រិត :

១. គ្រូនគរបាលជាតិ កម្រិតឧត្តម

២. គ្រូនគរបាលជាតិ កម្រិតមធ្យម

៣. គ្រូនគរបាលជាតិ កម្រិតបឋម

**មាត្រា៤ :** គ្រូនគរបាលជាតិត្រូវបានជ្រើសរើសក្នុងចំណោម មន្ត្រីនគរបាលជាតិទាំងពីរភេទ តាមរយៈការប្រឡងប្រជែង និងគ្រូនគរបាលជាតិទាំងពីរភេទ ដែលបានបង្ហាត់បង្រៀនកន្លងមក តាមរយៈការវាយតម្លៃរបស់ក្រសួងមហាផ្ទៃ ដោយផ្អែកលើលក្ខណៈសម្បត្តិរបស់គ្រូនគរបាលជាតិ ដែលមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ។

**មាត្រា៥ :** គ្រូនគរបាលជាតិជ្រើសរើសថ្មី ត្រូវទទួលការបណ្តុះបណ្តាលគរុកោសល្យ និងធ្វើកម្មសិក្សារយៈពេល៦ខែ ទើបធ្វើការតាំងស៊ប់ ជាគ្រូនគរបាលជាតិពេញសិទ្ធិ ។

**មាត្រា៦ :** លក្ខណៈសម្បត្តិគ្រូនគរបាលជាតិត្រូវបានកំណត់ដូចខាងក្រោម :

ក.គ្រូនគរបាលជាតិ កម្រិតឧត្តម

- មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬ សញ្ញាបត្រសមមូលឡើងទៅ
- មានអតីតភាពបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិយ៉ាងតិច៣ឆ្នាំ
- ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាលជំនាញនគរបាលក្នុងប្រទេស ឬ ក្រៅប្រទេស
- មានវិន័យ សីលធម៌ល្អ សុខភាពល្អ និងកាយសម្បទាមាំមួន

ខ.គ្រូនគរបាលជាតិ កម្រិតមធ្យម

- មានសញ្ញាបត្របរិញ្ញាបត្រ ឬ សញ្ញាបត្រសមមូល
- មានអតីតភាពបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិយ៉ាងតិច២ឆ្នាំ
- ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាលជំនាញនគរបាលក្នុងប្រទេស ឬក្រៅប្រទេស
- មានវិន័យ សីលធម៌ល្អ សុខភាពល្អ កាយសម្បទាមាំមួន

គ.គ្រូនគរបាលជាតិ កម្រិតបឋម

- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាបត្រសមមូល
- មានអតីតភាពបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិយ៉ាងតិច១ឆ្នាំ
- ធ្លាប់ឆ្លងកាត់ការបណ្តុះបណ្តាលជំនាញនគរបាលក្នុងប្រទេស ឬ ក្រៅប្រទេស
- មានវិន័យ សីលធម៌ល្អ សុខភាពល្អ កាយសម្បទាមាំមួន

**មាត្រា៧ :** ត្រូវបានចាត់ថ្នាក់គ្រូនគរបាលជាតិ ដូចខាងក្រោម :

- គ្រូនគរបាលជាតិ កម្រិតឧត្តម មាន ៤ ថ្នាក់
- គ្រូនគរបាលជាតិ កម្រិតមធ្យម មាន ៤ ថ្នាក់
- គ្រូនគរបាលជាតិ កម្រិតបឋម មាន ៤ ថ្នាក់

**មាត្រា៨** : ការតម្លើងថ្នាក់គ្រូនគរបាលជាតិ ត្រូវធ្វើឡើងទៅតាមវេនជ្រើសរើស ។ ប៉ុន្តែមិនអាចអនុវត្តបានប្រសិនបើគ្រូនគរបាលជាតិណាបម្រើការងារមិនគ្រប់តាមលក្ខខណ្ឌ និង រយៈពេលកំណត់។ រយៈពេលដែលត្រូវតម្លើងថ្នាក់មានដូចខាងក្រោម :

ក.គ្រូនគរបាលជាតិ កម្រិតឧត្តម មាន ៤ ថ្នាក់:

| កំណត់ថ្នាក់ | រយៈពេលបម្រើការងារក្នុងថ្នាក់នីមួយៗ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | ៦ ឆ្នាំ |
| ថ្នាក់លេខ ៣ | ៥ ឆ្នាំ |
| ថ្នាក់លេខ ៤ | ៥ ឆ្នាំ |

ខ.គ្រូនគរបាលជាតិ កម្រិតមធ្យម មាន ៤ថ្នាក់:

| កំណត់ថ្នាក់ | រយៈពេលបម្រើការងារក្នុងថ្នាក់នីមួយៗ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | ៥ ឆ្នាំ |
| ថ្នាក់លេខ ៣ | ៤ ឆ្នាំ |
| ថ្នាក់លេខ ៤ | ៤ ឆ្នាំ |

គ.គ្រូនគរបាលជាតិ កម្រិតបឋម មាន ៤ ថ្នាក់:

| កំណត់ថ្នាក់ | រយៈពេលបម្រើការងារក្នុងថ្នាក់នីមួយៗ |
|---|---|
| ថ្នាក់លេខ ១ | |
| ថ្នាក់លេខ ២ | ៤ ឆ្នាំ |
| ថ្នាក់លេខ ៣ | ៣ ឆ្នាំ |
| ថ្នាក់លេខ ៤ | ៣ ឆ្នាំ |

**មាត្រា៩** : ត្រូវបានកំណត់ឋានៈមូលដ្ឋានសំរាប់គ្រូនគរបាលជាតិ ដូចខាងក្រោម :

ក. គ្រូនគរបាលជាតិ កំរិតឧត្តម

- ថ្នាក់លេខ១ : មានឋានៈស្មើ អគ្គនាយករង
- ថ្នាក់លេខ២ : មានឋានៈស្មើ ប្រធាននាយកដ្ឋាន
- ថ្នាក់លេខ៣ : មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន
- ថ្នាក់លេខ៤ : មានឋានៈស្មើ នាយការិយាល័យ ចំណុះនាយកដ្ឋាន

ខ. គ្រូនគរបាលជាតិ កំរិតមធ្យម

- ថ្នាក់លេខ១ : មានឋានៈស្មើ ប្រធាននាយកដ្ឋាន
- ថ្នាក់លេខ២ : មានឋានៈស្មើ អនុប្រធាននាយកដ្ឋាន
- ថ្នាក់លេខ៣ : មានឋានៈស្មើ នាយការិយាល័យចំណុះនាយកដ្ឋាន

- ថ្នាក់លេខ៤ : មានឋានៈស្មើ នាយរងការិយាល័យចំណុះនាយកដ្ឋាន

គ.គ្រូនគរបាលជាតិ កំរិតបឋម

- ថ្នាក់លេខ១ : មានឋានៈស្មើ នាយការិយាល័យចំណុះនាយកដ្ឋាន
- ថ្នាក់លេខ២ : មានឋានៈស្មើ នាយរងការិយាល័យចំណុះនាយកដ្ឋាន
- ថ្នាក់លេខ៣ : មានឋានៈស្មើ នាយផ្នែកនៃការិយាល័យចំណុះនាយកដ្ឋាន
- ថ្នាក់លេខ៤ : មានឋានៈស្មើ នាយរងផ្នែកនៃការិយាល័យចំណុះនាយកដ្ឋាន

**មាត្រា១០** : ការតម្លើងឋានៈ គ្រូនគរបាលជាតិកំរិតឧត្តម ថ្នាក់លេខ១ , ថ្នាក់លេខ២ , និង គ្រូនគរបាលជាតិ កំរិតមធ្យម ថ្នាក់លេខ១ ត្រូវសំរេចដោយអនុក្រឹត្យ ។

ការតម្លើងឋានៈគ្រូនគរបាលជាតិ ក្រៅពីកំរិតនិងថ្នាក់ដែលមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា១១** : ឋានៈដូចមានចែងក្នុងមាត្រា៩ ខាងលើអនុវត្តសំរាប់តែមន្ត្រីនគរបាលជាតិ ជាគ្រូនគរបាលជាតិ ដែលស្ថិតនៅក្រោមមុខតំណែងដឹកនាំ ។

**មាត្រា១២**-: ការតម្លើងឋានន្តរសក្តិ គ្រូនគរបាលជាតិ ត្រូវអនុវត្តទៅតាមលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ។

**មាត្រា១៣** : គ្រូនគរបាលជាតិ ត្រូវទទួលបានប្រាក់កម្រៃគរុកោសល្យ តាមការកំណត់របស់រាជរដ្ឋាភិបាល ។

**មាត្រា១៤** : គ្រូនគរបាលជាតិ ត្រូវមានកិច្ចសន្យាបំរើការងារជាគ្រូបង្រៀននគរបាលជាតិ រយៈពេលយ៉ាងតិច១០ឆ្នាំទើបមានសិទ្ធិសុំទៅបំរើការងារនៅតាមអង្គភាពផ្សេងៗទៀតបាន ។

**មាត្រា១៥** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា១៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និង ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១១*

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា១៦*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៣៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២០ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៦៦អនក្រ.បកចុះថ្ងៃទី២២ខែតុលាឆ្នាំ១៩៩៧ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ០៥អនក្រ.ប.កចុះថ្ងៃទី២៨ខែមករាឆ្នាំ២០០៣ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាលនិងបណ្តុះបណ្តាលទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ១៨១អនក្រ.បកចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០០៨ស្តីពីការតម្លើងអធិការដ្ឋានទៅជាអគ្គាធិការដ្ឋាន នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### <u>ស ម្រេ ច</u>

**មាត្រា ១ :** ប្រគល់ភារកិច្ចជូនលោក **អ៊ូ ម៉ូរ៉ាត់** ជាអគ្គាធិការរងនៃអគ្គាធិការដ្ឋានក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

**មាត្រា២:** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល:**</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១១៣៦ អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- យោងតាមតម្រូវការការងារ

## សម្រេច

**មាត្រា ១ ៖** ត្រូវបានដំឡើងឋានន្តរស័ក្តិមន្ត្រី ចំនួន ០៣ រូប នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅទីស្តីការគណៈរដ្ឋមន្ត្រី មានដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម | ជួន ជីវិន | ពី អនុមន្ត្រី ថ្នាក់លេខ ១១ ទៅ វរមន្ត្រី ថ្នាក់លេខ ១០ |
| ២- លោកជំទាវ | មាស វិចិត្រ | ពី អនុមន្ត្រី ថ្នាក់លេខ ១១ ទៅ វរមន្ត្រី ថ្នាក់លេខ ១០ |
| ៣- លោកជំទាវ | គង់ ម៉ារីយ៉ | ពី អនុមន្ត្រី ថ្នាក់លេខ ១១ ទៅ វរមន្ត្រី ថ្នាក់លេខ ១០ |

**មាត្រា ២ ៖** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុង មាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៣៧-អនក្រ-បក

# អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់មេដាយ **មាស** ការងារ ជាកិច្ចបច្ឆាមរណៈ ជូនដល់សពមន្ត្រីនគរបាលជាតិចំនួន ០២ នាក់ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ដែលបានពលីជីវិតដោយការបង្ក្រាបចោរប្លន់ប្រដាប់អាវុធ កាលពីថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០១១ វេលាម៉ោង ០២ : ៤០ នាទី រំលងអាធ្រាត ដូចមានរាយនាមខាងក្រោម ៖

១ លោកអនុសេនីយ៍ត្រី គង់ វិចិត្រ អត្តលេខ ៦៧៩៣៥ មន្ត្រី នៃការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់

២ លោកព្រិន្ទបាលទោ រឿន ប៉ូ អត្តលេខ ៣៩៨៩៩ មន្ត្រី នៃការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ១១ ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១១៣៨ . អនក្រ-តតត**

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

